**ចំណងចងភ្ជាប់ពិតប្រាកដ (Genuine Link)**

ចំណងរវាងបុគ្គល និងរដ្ឋ តាមរយៈ សញ្ជាតិ ដែលជាចំណងផ្លូវច្បាប់ (legal bond) ។ វិធានផ្តល់សញ្ជាតិ មិនត្រូវបានទាមទារ ឲ្យទទួលស្គាល់ ដោយរដ្ឋដទៃ ទាល់តែ ផ្អែកតាមចំណងភ្ជាប់ពិតប្រាកដ (សញ្ជាតិ) ដែលអនុញ្ញាតឲ្យរដ្ឋនេះ អាចការពារប្រជាពលរដ្ឋ ទល់នឹងការបំពានរបស់រដ្ឋផ្សេង។

រីឯចំណង រវាងជនបរទេស និង រដ្ឋមួយ ដែលជាចំណងពិតប្រាកដធម្មតា។ បុគ្គលមានសញ្ជាតិតែមួយ ក៏ប៉ុន្តែ មិនមានចំណងមានប្រសិទ្ធភាព (effective link) ជាមួយរដ្ឋសញ្ជាតិ មិនអាចត្រូវបានគេបដិសេធ មិនឲ្យពឹងលើរដ្ឋដែលខ្លួនមានសញ្ជាតិនោះទេ ទោះបីជាគាត់មានចំណងពិតប្រាកដជាមួយរដ្ឋទីបីក្តី។

សម្រាប់កប៉ាល់ កប៉ាល់ ដែលមានសញ្ជាតិប្រទេសណាមួយ តាមរយៈការចុះបញ្ជី និងអាចធ្វើដំណើរដោយប្រើទង់ជាតិរដ្ឋនោះ។ កប៉ាល់ និងរដ្ឋ ត្រូវមានចំណងពិតប្រាកដ ស្តែងឡើងតាមការអនុវត្តយុត្តាធិការមានប្រសិទ្ធភាព ការគ្រប់គ្រងរដ្ឋបាល ឬបច្ចេកទេសលើកប៉ាល់នោះ។ ទោះបីជាយ៉ាងនេះក្តី មានការរិះគន់ចំពោះ លក្ខខណ្ឌដ៏តឹងរឹងនេះ។ អាស្រ័យហេតុនេះ អនុសញ្ញា ឈីហ្គាហ្គូ ស្តីពីនាវាចរណស៊ីវិល ឆ្នាំ ១៩៤៤ មិនទាមទារលក្ខខណ្ឌចំណងពិតប្រាកដទេ (Encyclopedia Dictionary of IL, Genuine Link, pp. 243-244)។